ក្រដាសព័ត៌មាននេះគឺសំរាប់**គ្រប់ខោនធីទាំងអស់** លើកលែងតែខោនធីមែឌីរា ណាផា នេវ៉ាដា សេនមែធីអូ និង ស៊ៃគ្រែមែនតូ។

ដឹងអំពី

សិទ្ធិបោះឆ្នោតរបស់អ្នក

តើខ្ញុំអាចបោះឆ្នោតនៅក្នុងការ បោះឆ្នោតលើកនេះបានទេ?

តើខ្ញុំចាប់ផ្តើមរបៀបណា?

ដើម្បីបោះឆ្នោតបាន ដំបូងអ្នកត្រូវ "ចុះឈ្មោះ" បោះឆ្នោត! អ្នកអាចចុះឈ្មោះបានប្រសិនបើអ្នក:

- មានសញ្ជាតិអាមេរិកាំង
- ជាអ្នកមានទីលំនៅស្របច្បាប់នៅរដ្ឋកាលីហ្វ័រនា
- នឹងមានអាយុ18ឆ្នាំ ឬ ច្រើនជាងនេះនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្នមិនជាប់គុក ឬ មិនត្រូវបានដោះលែងជាបណ្តោះអាសន្នពីការផ្តន្ទាទោសពីបទឧក្រិដ្ឋ ហើយ
- មិនត្រូវបានតុលាការយល់ថា "មិនមានសមត្ថភាពផ្នែកស្មារតី"

តើខ្ញុំចុះឈ្មោះបោះឆ្នោតរបៀបណា?

ថ្ងៃផុតកំណត់គឺ 15 ថ្ងៃមុនថ្ងៃបោះឆ្នោត: **ថ្ងៃទី22 ខែតុលា ឆ្នាំ** 2018។ អ្នកអាចចុះឈ្មោះ:

- នៅលើអ៊ិនធឺនែត www.registertovote.ca.gov:
- នៅការិយាល័យធ្វើអត្តសញ្ញាណប័ណ ការិយាល័យប្រៃសណីយ៍ បណ្ណាល័យ ឬ នៅការិយាល័យ បោះឆ្នោតរបស់ខោនធីអ្នក ឬ
- ដោយទូរស័ព្ទមកលេខ 800-345-VOTE (8683) ដើម្បីស្នើរសុំទំរង់ចុះឈ្មោះបោះឆ្នោត។

តើវាយ៉ាងម៉េចទៅវិញបើខ្ញុំមិនដឹងថាបានចុះឈ្មោះបោះឆ្នោតឬនៅ?

អ្នកអាចពិនិត្យមើលតាមអ៊ិនធឺនែតបានដើម្បីអោយដឹងថាអ្នកបានចុះឈ្មោះឬនៅ នៅ https://voterstatus.sos.ca.gov។ បើអ្នកមិនប្រាកដ អ្នកអាចចុះឈ្មោះបានម្តងទៀត។ អ្នកគួរតែចុះឈ្មោះម្តងទៀតដែរ បើអ្នកប្តូរឈ្មោះឬ អស័យដ្ឋានរបស់អ្នក។

អាស៊ីអាមេរិកាំង
កៃលំអយុត្តិធម៌
កាលីហ្វ័រនា

កាលីហ្វ័រនា 2018

ការបោះឆ្នោតទូទៅ:
ថ្ងៃអង្គារ ទី6 ខែវិច្ឆិកា ឆ្នាំ 2018
ថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោត:
ថ្ងៃច័ន្ទ ទី22 ខែតុលា ឆ្នាំ 2018

តើវាយ៉ាងម៉េចទៅវិញបើខ្ញុំមិនបានធ្វើទាន់ថ្ងៃផុតកំណត់?

បើអ្នកមិនបានធ្វើទាន់ថ្ងៃផុតកំណត់គឺថ្ងៃទី22 ខែតុលា ឆ្នាំ 2018 ទេ អ្នកនៅតែអាចចុះឈ្មោះបោះឆ្នោតតាមរយៈ "ការចុះឈ្មោះបោះឆ្នោតដោយមានលក្ខខណ្ឌ" (CVR) ដែលអនុញ្ញាតអោយអ្នកចុះឈ្មោះហើយនិង បោះឆ្នោត (ក្នុងពេលតែមួយ) គឺក្រោយថ្ងៃកំណត់ចុះឈ្មោះបោះឆ្នោត។ តែទោះជាយ៉ាងនេះក៏ដោយ CVR គឺមានតែក្នុងទីតាំងខោនធីមួយចំនួនប៉ុណ្ណោះ រួមទាំងការិយាល័យ បោះឆ្នោតនៅក្នុងខោនធីរបស់អ្នក។ សូមពិនិត្យមើលអោយដឹងថាតើ CVR មានផ្តល់ជូននៅកន្លែងណាខ្លះដោយទាក់ទងទៅការិយាល័យ បោះឆ្នោតក្នុងខោនធីរបស់អ្នក: www.sos.ca.gov/countv-elections-offices.

តើខ្ញុំត្រូវតែជ្រើសរើសគណបក្សនយោបាយមួយមែនឬទេ?

មិនមែនទេ បើអ្នកចង់ឯករាជ្យ អ្នកអាចចុះឈ្មោះដោយជ្រើសរើស "គ្មានទំនោរចិត្តលើគណបក្សណា" ឬទុកផ្នែកនោះចំហចោល។ សូមប្រយ័ត្ន! ការចុះឈ្មោះជាមួយគណបក្សអាមេរិកាំងឯករាជ្យគឺមិនដូចជាការចុះឈ្មោះឯករាជ្យទេ។

តើខ្ញុំបោះឆ្នោតរបៀបណានៅថ្ងៃបោះឆ្នោត?

ថ្ងៃបោះឆ្នោតគឺថ្ងៃអង្គារ ទី6 ខែវិច្ឆិកា ឆ្នាំ2018។ កន្លែងបោះឆ្នោតនឹងបើកពីម៉ោង7ព្រឹកដល់ម៉ោង 8យប់។
ដើរទៅកន្លែង បោះឆ្នោតរបស់អ្នក រកតុធំ ហើយប្រាប់ឈ្មោះនិងអស័យដ្ឋានរបស់អ្នកទៅបុគ្គលិក (ត្រូវបានស្គាល់ផងដែរថា "បុគ្គលិក បោះឆ្នោត")។ សួរបុគ្គលិក បោះឆ្នោតទាំងនោះថាតើមានសន្លឹកឆ្នោតជាភាសាដែលអ្នកចូលចិត្តដែរទេ។

តើខ្ញុំបោះឆ្នោតនៅកន្លែងណា?

ការណែនាំព័ត៌មានសំរាប់អ្នក បោះឆ្នោតនៅខោនធីរបស់អ្នក (ត្រូវបានស្គាល់ផងដែរថា "សន្លឹកឆ្នោតប៉ាន់គំរូ") ដែលអ្នកទទួលបានពីការិយាល័យ បោះឆ្នោតនៅខោនធីរបស់អ្នកនៅមុនពេលបោះឆ្នោតនឹងមានរាយក្នុងតារាងនូវកន្លែង បោះឆ្នោតដែលបានកំណត់រួច។ អ្នកក៏អាចរកឃើញកន្លែង បោះឆ្នោតរបស់អ្នកនៅទីនេះផងដែរ: www.sos.ca.gov/elections/polling-place.

សំរាប់ការសូមជំនួយពីមន្ត្រី បោះឆ្នោតជាន់ខ្ពស់របស់កាលីហ្វ័រនាសូមទូរស័ព្ទមក: **800-345-VOTE** (8683)។

ក្រដាសពត៌មាននេះគឺសំរាប់**គ្រប់ខោនធីទាំងអស់** លើកលែងតែខោនធីមែឌីរា ណាផា នេវ៉ាដា ស៊ែនមែធីអូ និង ស៊ែគ្រែមែនតូ។

តើខ្ញុំត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំទេនៅពេល បោះឆ្នោត?
អ្នកគ្រាន់តែត្រូវបង្ហាញអត្តសញ្ញាណរបស់អ្នកមុនពេល បោះឆ្នោតនៅកាលីហ្វ័រនាតែប៉ុណ្ណោះ បើអ្នកមិនបានបង្ហាញ អត្តសញ្ញាណនៅពេលចុះឈ្មោះ បោះឆ្នោត។ ឯកសារជាច្រើន នឹងគ្រប់គ្រាន់ហើយ។ សូមទូរស័ព្ទទៅការិយាល័យ បោះឆ្នោត អ្នកមុនពេល បោះឆ្នោតបើសិនអ្នកមានសំនួរ។

តើខ្ញុំអាចនាំនរណាម្នាក់ទៅជួយខ្ញុំបោះឆ្នោតបានទេ?
បាន។ ច្បាប់របស់កាលីហ្វ័រនាអនុញ្ញាតិអោយអ្នកនាំមនុស្ស ដល់ទៅពីរនាក់ទៅជួយអ្នកនៅកន្លែង បោះឆ្នោត ដរាបណា អ្នកទាំងនោះមិនតំណាងអោយកន្លែងធ្វើការរបស់អ្នក ឬ សហជីពរបស់អ្នក។ សូមនាំសមាជិកគ្រួសារ ឬ មិត្តរបស់អ្នក មក។

តើវាយ៉ាងម៉េចទៅវិញបើខ្ញុំមានបញ្ហានៅកន្លែង បោះឆ្នោត របស់ខ្ញុំ?
កុំបោះបង់ការ បោះឆ្នោតចោល! បើបុគ្គលិក បោះឆ្នោត និយាយថាវាមានបញ្ហា សូមសួររកសន្លឹកឆ្នោតបណ្តោះអាសន្ន ដែលវាជាសន្លឹកឆ្នោតដូចសន្លឹកឆ្នោតធម្មតាតែត្រូវបានរាប់ ក្រោយពេលមន្ត្រី បោះឆ្នោតបានបញ្ជាក់ពីសិទ្ធិ បោះឆ្នោត របស់អ្នក ឬ ទូរស័ព្ទមកលេខការពារអ្នក បោះឆ្នោតនៅថ្ងៃ បោះឆ្នោតណាមួយក្នុងចំណោមលេខខាងក្រោមៈ

- **866-OUR-VOTE (866-687-8683)** សំរាប់ជំនួយ ផ្នែកភាសាអង់គ្លេស។
- **888-API-VOTE (888-274-8683)** សំរាប់ជំនួយ ផ្នែកភាសាអង់គ្លេស និង ភាសាអាស៊ី។
- **888-Ve-Y-Vota (888-839-8682)** NALEO លេខមិនគិតថ្លៃរបស់មូលនិធិអប់រំជាភាសាអេស្ពាញនិង អង់គ្លេស។

តើខ្ញុំ បោះឆ្នោតដោយសំបុត្រតាមរបៀបណា?
នៅពេលចុះឈ្មោះ បោះឆ្នោត អ្នកអាចចុះឈ្មោះ បោះឆ្នោតតាមសំបុត្រ។ បើអ្នកជ្រុលចុះឈ្មោះ បោះឆ្នោតរួច ហើយ អ្នកអាចយកពាក្យចុះឈ្មោះ បោះឆ្នោតតាមរយៈសំបុត្រពី www.sos.ca.gov/elections/voter-registration/ vote-mail. បើអ្នកចុះឈ្មោះ បោះឆ្នោតតាមសំបុត្រ ការិយាល័យ បោះឆ្នោតខោនធីនឹងផ្ញើរសន្លឹកឆ្នោតជូនអ្នកប្រហែលមួយខែមុន ថ្ងៃ បោះឆ្នោត។

តើថ្ងៃផុតកំណត់ផ្ញើរសន្លឹកឆ្នោតទៅវិញគឺថ្ងៃណាដែរ?
បើអ្នកផ្ញើរសន្លឹកឆ្នោតមកវិញតាមរយៈប្រៃសណីយ៍ វាត្រូវតែ បោះត្រាត្រឹមថ្ងៃ បោះឆ្នោត។ អ្នកក៏អាចយកវាមកទំលាក់នៅកន្លែង បោះឆ្នោតណាមួយនៅខោនធីអ្នកមុនម៉ោង៨យប់នៅថ្ងៃ បោះឆ្នោត។ សូមចងចាំថាត្រូវចុះហត្ថលេខានិងសរសេរកាលបរិច្ឆេទលើសន្លឹក ឆ្នោតដែលត្រូវផ្ញើរតាមប្រៃសណីយ៍ដើម្បីអោយគេអាចចាត់ទុកវាជា ការបាន។

តើខ្ញុំនឹងអាច បោះឆ្នោតជាភាសាផ្សេងពីអង់គ្លេស បានទេ?
ជំនួយផ្នែកភាសាខុសគ្នាពីខោនធីមួយទៅខោនធីមួយ។ សូម ទូរស័ព្ទទៅការិយាល័យ បោះឆ្នោតខោនធីរបស់អ្នក ដើម្បីអោយ ដឹងថាមានអ្វីជាភាសាដែលអ្នកចូលចិត្តក្នុងខោនធីរបស់អ្នក។ នៅថ្ងៃ បោះឆ្នោត នៅកន្លែង បោះឆ្នោតរបស់អ្នក សូមសួរថាតើ មានឯកសារដែលបកប្រែរួចឬទេ ហើយសួរថាតើបុគ្គលិកដែល នៅទីនោះនិយាយភាសាដែលអ្នកចូលចិត្តឬទេ។ ភាសាដែល អាចផ្តល់ជូននៅខោនធីរបស់អ្នករួមមានៈ

អារ៉ាប់	អាម៉ានៀន	អាស្សីរី (ស៊ីរី)	ខ្មែរ
ចិន	អ៊ីរ៉ង់	ហ្វីលីពីន/ តាកាឡុក	ម៉ុង
អ៊ីឡូកាណូ	កូរេ	ភុនចាប៊ី	អេស្ពាញ
វៀតណាម	ជប៉ុន(LA តែប៉ុណ្ណោះ)	ហ៊ីនឌី (LA តែប៉ុណ្ណោះ)	ថៃ (LA តែប៉ុណ្ណោះ)

ខោនធីពិសេសៗ
ខោនធីមែឌីរា ណាផា នេវ៉ាដា ស៊ែគ្រែមែនតូ និង ស៊ែនមែធីអូ កំពុងតែអនុវត្តប្រព័ន្ធ បោះឆ្នោតថ្មីនៅក្រោមច្បាប់ជំរើសរបស់ អ្នក បោះឆ្នោត។ អ្នកអាចស្វែងរកពត៌មានបន្ថែមស្តីពីប្រព័ន្ធ បោះឆ្នោតថ្មីនេះ ដោយធ្វើទំនាក់ទំនងជាមួយអង្គការ ខាងក្រោម។

អាស៊ីអាមេរិកាំង
កែលំអយុត្តិធម៌
កាលីហ្វ័រនា

អាស៊ីអាមេរិកាំងកែលំអយុត្តិធម៌ - កាលីហ្វ័រនា ការពារសិទ្ធិបោះឆ្នោតរបស់ អាស៊ីអាមេរិកាំង ឡាទីណូ និង សហគមន៍អន្តោប្រវេសន៍នានា។
អាស៊ីអាមេរិកាំងកែលំអយុត្តិធម៌ - ការប្រជុំច្បាប់អាស៊ី
55 Columbus Avenue, San Francisco, CA 94111
www.advancingjustice-alc.org (415) 896-1701
Jonathan Stein មេធាវីនិងអ្នកចាត់ការកម្មវិធី កម្មវិធីសិទ្ធិ បោះឆ្នោតៈ
ionathans@advancingjustice-alc.org
អាស៊ីអាមេរិកាំងកែលំអយុត្តិធម៌ - ឡូសអែនជែលែស
1145 Wilshire Blvd, Los Angeles, CA 90017
www.advancingiustice-la.org (213) 977-7500
Deanna Kitamura នាយកគំរោង គំរាងសិទ្ធិ បោះឆ្នោតៈ
dkitamura@advancingjustice-la.org

សំរាប់ការសូមជំនួយពីមន្ត្រី បោះឆ្នោតជាន់ខ្ពស់របស់កាលីហ្វ័រនាសូមទូរស័ព្ទមកៈ **800-345-VOTE** (8683)។